**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ០៥ សរណន

**សារាចរណែនាំ**

**ស្តីពី**

**ការបញ្ចូលប្រាក់គ្រូបង្រៀនពីរវេន និងប្រាក់គ្រូបង្រៀនថ្នាក់គួប នៅក្នុងតារាងទូទាត់បៀវត្ស តាមប្រព័ន្ធព័ត៌មានវិទ្យា**

វិស័យអប់រំជាវិស័យអាទិភាពដែលរាជរដ្ឋាភិបាលតែងតែយកចិត្តទុកដាក់ និងប្រើប្រាស់គ្រប់មធ្យោបាយទាំងអស់ដើម្បីដោះស្រាយបញ្ហាលំបាកទាំងឡាយជាពិសេសលោកគ្រូ អ្នកគ្រូ ព្រមទាំងបុគ្គលិកសិក្សាទាំងអស់ ។

ចាប់តាំងពីឆ្នាំ ២០០១ រាជរដ្ឋាភិបាលបានដាក់ឱ្យអនុវត្តនូវប្រព័ន្ធបៀវត្សតាមប្រព័ន្ធព័ត៌មានវិទ្យា ដែលជាមធ្យោបាយគ្រប់គ្រងយ៉ាងមានប្រសិទ្ធភាពសំរាប់គ្រប់គ្រងលើការប្រែប្រួលស្ថានភាពមន្ត្រីរាជការ និងធានាបានលើការបើកផ្តល់បៀវត្សជូនមន្ត្រីរាជការឱ្យមានសុក្រឹត្យភាព និងបានទាន់ពេលវេលា ។ ក្នុងន័យនេះដើម្បីបន្តពង្រឹងប្រសិទ្ធភាពក្នុងការគ្រប់គ្រង ក៏ដូចជាធានាឱ្យមានភាពរលូន និងមានសុក្រឹត្យភាពក្នុងការបើកផ្តល់បៀវត្សជូនមន្ត្រីរាជការស៊ីវិលទាំងអស់ ជាពិសេសប្រាក់របស់គ្រូបង្រៀនដែលបានបង្រៀនពីរវេន និងបង្រៀនថ្នាក់គួប រាជរដ្ឋាភិបាលសូមធ្វើការណែនាំដូចខាងក្រោម :

១- ប្រាក់គ្រូបង្រៀនពីរវេន និងប្រាក់គ្រូបង្រៀនថ្នាក់គួបទាំងអស់ដែលធ្លាប់តែបើកក្រៅប្រព័ន្ធបៀវត្សតាមប្រព័ន្ធព័ត៌មានវិទ្យាត្រូវបញ្ឈប់នៅដំណាច់ឆ្នាំសិក្សា ២០០៦-២០០៧ ហើយចាប់ពីបវេសនកាលឆ្នាំ ២០០៧-២០០៨ តទៅ ក្រសួងអប់រំ យុវជន និងកីឡាត្រូវអនុវត្តការបើកប្រាក់ទាំងពីរប្រភេទនេះតាមតារាងបៀវត្សតាមប្រព័ន្ធព័ត៌មានវិទ្យាដូចប្រាក់បៀវត្សមន្ត្រីរាជការទូទៅដែរ ។

២- នៅខែតុលាដើមបវេសនកាលរៀងរាល់ឆ្នាំ ក្រសួងអប់រំយុវជន និងកីឡា ត្រូវរៀបចំសំណុំលិខិតបទដ្ឋានគតិយុត្តិផ្សេងៗ ពាក់ព័ន្ធនឹងការជ្រើសរើស ឬការចាត់តាំងគ្រូបង្រៀនពីរវេន និងគ្រូបង្រៀនថ្នាក់គួប ស្នើសុំទៅស្ថាប័នសមត្ថកិច្ចពាក់ព័ន្ធឱ្យបានទាន់ពេលវេលា ។

៣- ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាលត្រូវរៀបចំបញ្ចូលប្រាក់គ្រូបង្រៀនពីរវេន និងប្រាក់គ្រូបង្រៀនថ្នាក់គួបទៅក្នុងតារាងទូទាត់បៀវត្សតាមប្រព័ន្ធព័ត៌មានវិទ្យា បន្ទាប់ពីបានទទួលឯកសារផ្លូវការពីក្រសួងអប់រំយុវជន និងកីឡា ។

៨- ក្នុងករណីចាំបាច់ដើម្បីធានាមិនឱ្យមានបាតុភាពកើតឡើង និងដើម្បីធានាឱ្យការបញ្ចូលប្រាក់ទាំងពីរប្រភេទនេះក្នុងតារាងទូទាត់បៀវត្សតាមប្រព័ន្ធព័ត៌មានវិទ្យាបានប្រព្រឹត្តិទៅដោយភាពរលូន នោះក្រសួងអប់រំ យុវជន និងកីឡា ត្រូវសហការជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និងក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាលចុះត្រួតពិនិត្យជាក់ស្តែងនៅតាមមូលដ្ឋាន ។

៩- ក្រសួងអប់រំយុវជន និងកីឡា ត្រូវគ្រោងថវិកាប្រចាំឆ្នាំឱ្យរួចស្រេច សម្រាប់ការប្រើប្រាស់គ្រូបង្រៀនពីរវេន និងគ្រូបង្រៀនថ្នាក់គួប ។ ជាពិសេសត្រូវរៀបចំសេចក្តីណែនាំស្តីពីនីតិវិធីនៃការប្រើប្រាស់គ្រូបង្រៀនពីរវេន និងគ្រូបង្រៀនថ្នាក់គួប ។

ទទួលបានសារាចរណែនាំនេះ ក្រសួងអប់រំយុវជន និងកីឡា ព្រមទាំងស្ថាប័នសមត្ថកិច្ចពាក់ព័ន្ធទាំងអស់ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងអប់រំយុវជន និងកីឡា
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល
- ឯកសារ-កាលប្បវត្តិ